## កម្ពុជា៖ កង្វះការពិគ្រោះយោបល់លើច្បាប់សំខាន់ៗ បង្កើតជាលំនាំគួរឲ្យព្រួយបារម្ភសម្រាប់ការធ្វើច្បាប់ដទៃទៀតនៅថ្ងៃអនាគត អ្នកជំនាញការ អ.ស.ប បានព្រមានដូច្នេះ

**ទីក្រុងហ្សឺណែវ** (២៧ ខែឧសភា ឆ្នាំ២០១៤) - *បន្ទាប់ពីការអនុម័តច្បាប់គ្រឹះទាំងបីស្តីពីប្រព័ន្ធតុលាការដោយរដ្ឋសភាកម្ពុជា កាលពីសប្តាហ៍មុននេះមក អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា លោក សុរិយា ប្រាសាទ ស៊ូប៊ែឌី បានព្រមានថា ការខ្វះដំណើរការពិគ្រោះយោបល់ទាក់ទងនឹងសេចក្តីព្រាងច្បាប់ទាំងបីនេះ បានបង្កើតជាលំនាំមួយគួរឲ្យព្រួយបារម្ភសម្រាប់ការធ្វើច្បាប់សំខាន់ៗដទៃទៀតនៅថ្ងៃអនាគត៖*

" រយៈពេលជាច្រើនឆ្នាំ ក្នុងសមត្ថភាពរបស់ខ្ញុំជាអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ខ្ញុំបានបន្តជម្រុញឲ្យមានការ * ការអនុម័តច្បាប់គ្រឹះទាំងបីនេះ ស្តីពីប្រព័ន្ធតុលាការដោយគ្មានការពន្យាពេលតទៅទៀត។ ច្បាប់ទាំងនេះ គឺជាស្នូលនៃអនុសាសន៍ក្នុងរបាយការណ៍ឆ្នាំ២០១០ របស់ខ្ញុំ ដែលខ្ញុំបានផ្តោតលើកំណែទម្រង់ប្រព័ន្ធតុលាការ។ ដូច្នេះ ជាគោលការណ៍ ខ្ញុំសូមស្វាគមន៍ការអនុម័តច្បាប់ទាំងនេះ ដោយរដ្ឋសភាកម្ពុជា។

ទោះជាយ៉ាងណាដោយ ខ្ញុំបានគូសបញ្ជាក់ជាច្រើនលើកច្រើនសារផងដែរ អំពីការអនុម័តច្បាប់ឆាប់រហ័សនេះ មិនត្រូវឲ្យឃ្លាតចេញពីគោលការណ៍គន្លឹះនៃដំណើរការធ្វើច្បាប់ដែលក្នុងនោះរួមមាន តម្លាភាព គណនេយ្យភាព និងការចូលរួម ឡើយ។

ខ្ញុំត្រូវបានលើកទឹកចិត្ត ដោយការដែលថា នៅក្នុងឆ្នាំ២០១២ រដ្ឋាភិបាលបានសន្យាចំពោះដៃគូអភិវឌ្ឍន៍ទាំងឡាយ ដែលចូលរួមក្នុងដំណើរការធ្វើកំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ ថា ខ្លួននឹងរៀបចំឲ្យមានការពិគ្រោះយោបល់ជាសាធារណៈលើសេចក្តីព្រាងច្បាប់ទាំងបីនេះ។

គឺនៅក្នុងបរិបទនេះហើយ ដែលខ្ញុំមានការសោកស្តាយជាខ្លាំង ព្រោះថា បើទោះជាមានការសន្យានេះ និងមានការអំពាវនាវម្តងហើយម្តងទៀតពីខ្ញុំ រួមទាំងពីសង្គមស៊ីវិលនានា ឲ្យមានការពិគ្រោះយោបល់ជាសាធារណៈក្តី ក៏រដ្ឋាភិបាលមិនបានចែករំលែកសេចក្តីព្រាងច្បាប់ទាំងបីនេះ ទាំងជាសាធារណៈ ទាំងរហូតដល់មួយថ្ងៃមុនពេលរដ្ឋសភា បានចាប់ផ្តើមពិភាក្សាលើសេចក្តីព្រាងទាំងនេះ នោះក៏ទេដែរ ។

សេចក្តីព្រាងច្បាប់គ្រឹះទាំងបីនេះ តំណាងឲ្យឱកាសតែមួយគត់ ដើម្បីបញ្ជាក់ការធានាដ៏រឹងមាំចំពោះឯករាជ្យភាពនៃប្រព័ន្ធតុលាការ។ កាលពីពេលកន្លងមក ខ្ញុំធ្លាប់បានផ្តល់ជាអនុសាសន៍ថា ច្បាប់នេះមានគោលដៅហាមប្រាមដាច់ខាត ដល់ចៅក្រម និងព្រះរាជអាជ្ញា ធ្វើជាសមាជិកសកម្មនៃគណបក្សនយោបាយណាមួយ។ ខ្ញុំមានកង្វល់ថា សេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា មិនមានបញ្ញត្តិណាមួយហាមប្រាមចំពោះបញ្ហានេះទេ។

ខ្ញុំមានកង្វល់ជាខ្លាំងផងដែរ អំពីការដែលថា ក្រសួងយុត្តិធម៌ ត្រូវបានផ្តល់សិទ្ធិអំណាចមួយចំនួនលើស្ថាប័នតុលាការ។ ដើម្បីរក្សាឯករាជ្យភាពនៃតុលាការ គេមិនគួរឲ្យមានសមាជិកនៃអង្គនីតិប្រតិបត្តិណាមួយពាក់ព័ន្ធក្នុងការងារតែងតាំង និងការដំឡើងឋានៈចៅក្រម ឬការដាក់វិន័យចៅក្រមឡើយ។

កង្វះនៃដំណើរការពិគ្រោះយោបល់លើសេចក្តីព្រាងច្បាប់គ្រឹះទាំងនេះ ពិតជាបានបង្កើតឲ្យមានកង្វល់អំពីការយកលំនាំតាមសម្រាប់ការធ្វើច្បាប់សំខាន់ៗដទៃទៀត នៅថ្ងៃអនាគត។ ខ្ញុំបន្តអំពាវនាវដល់រដ្ឋាភិបាលឲ្យធ្វើការចែករំលែកសេចក្តីព្រាងច្បាប់ទាំងអស់ ឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន ដើម្បីទទួលបានសេចក្តីផ្តល់មតិពីសាធារណៈជន និងពីអ្នកជំនាញផ្សេងៗទៀត នៅមុនពេលបញ្ជូនសេចក្តីព្រាងច្បាប់ទាំងនោះទៅទីស្តីការគណៈរដ្ឋមន្ត្រីពិនិត្យ ជាពិសេស សេចក្តីព្រាងច្បាប់ទាំងឡាយណាដែលមានផលប៉ះពាល់ដល់ការអនុវត្តសិទ្ធិ និងការទទួលបានសិទ្ធិមនុស្ស។ ខ្ញុំអំពាវនាវផងដែរ ដល់រដ្ឋសភា សូមឲ្យអនុវត្តដូចគ្នានេះដែរ នូវសេចក្តីព្រាងច្បាប់ទាំងអស់ដែលមាន ឬដែលនឹងមាននៅចំពោះមុខរដ្ឋសភា។

ទន្ទឹមនឹងច្បាប់ទាំងបីដែលបានអនុម័តនេះ មិនបំពេញតាមបទដ្ឋានអន្តរជាតិ ដែលតម្រូវឲ្យប្រព័ន្ធតុលាការឯករាជ្យពិតប្រាកដនោះ គេគួរតែរំលឹកឡើងវិញថា ការធ្វើច្បាប់គឺជាដំណើរការមួយដែលបង្កើតអង្គការ និងមានការវិវត្តន៍ជានិច្ច។ ក្នុងស្មារតីនេះហើយ ដែលខ្ញុំអំពាវនាវដល់ព្រឹទ្ធសភា និងក្រុមប្រឹក្សាធម្មនុញ្ញ សូមធ្វើការពិនិត្យពិចារណាឲ្យបានដិតដល់អំពីកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិ ដែលកម្ពុជាបានទទួលយកដោយស្ម័គ្រចិត្ត និងធានាថា ច្បាប់ទាំងបីនេះ ត្រូវអនុលោមទាំងស្រុងទៅនឹងកាតព្វកិច្ចទាំងនេះ៉ ។

(*) អ្នករាយការណ៍ពិសេសបានបញ្ជូនអនុសាសន៍របស់លោក នៅក្នុងរបាយការណ៍សំខាន់ៗចំនួនប្រាំ ទៅក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ហើយនឹងបង្ហាញរបាយការណ៍ជាបន្តបន្ទាប់ទៀត របស់លោក ទៅក្រុមប្រឹក្សាសិទ្ធិមនុស្ស នៅខែកញ្ញា ឆ្នាំ២០១៤ ។ សូមពិនិត្យមើលរបាយការណ៍លើមុនៗរបស់លោក៖ http://ap.ohchr.org/documents/dpage_e.aspx?m=107

## ចប់

*លោកសាស្ត្រាចារ្យ សុរិយា ប្រាសាទ ស៊ូប៊ែឌី ត្រូវបានក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប តែងតាំងជាអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ក្នុងខែមីនា ឆ្នាំ២០០៩។ ក្នុងនាមជាអ្នករាយការណ៍ពិសេស លោកជាបុគ្គលឯករាជ្យ មិនចំណុះរដ្ឋាភិបាល ឬអង្គការណាមួយឡើយ ហើយបំរើការក្នុងសមត្ថភាពបុគ្គលលោកផ្ទាល់។ បច្ចុប្បន្ន លោកជា*

*សាស្ត្រាចារ្យផ្នែកនីតិអន្តរជាតិនៃសាកលវិទ្យាល័យលីដស៍ ចក្រភពអង់គ្លេស និងជាមេធាវីអាជីពមួយរូបនៃគណៈមេធាវីមីឌ្រីលថឹមភីល នៅទីក្រុងឡុង។ លោកជាអនុប្រធានសង្គមអាស៊ីនៃនីតិអន្តរជាតិ និងជាអ្នកនិពន្ធសៀវភៅពាក់ព័ន្ធនឹងគម្រោងសំខាន់ៗ ទស្សនាវដ្ដីអាស៊ីនៃច្បាប់អន្តរជាតិ បោះពុម្ពផ្សាយដោយរោងពុម្ពនៃសាកលវិទ្យាល័យខេមប្រីដជ៍។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រនេះ*
*http://www.ohchr.org/EN/HRBodies/SP/CountriesMandates/KH/Pages/SRCambodia.aspx*

*សិទ្ធិមនុស្ស អ.ស.ប គេហទំព័រប្រទេស – កម្ពុជា៖*

*http://www.ohchr.org/EN/Countries/AsiaRegion/Pages/KHIndex.aspx*

*សម្រាប់ព័ត៌មានបន្ថែម និង**ការសាកសួរព័ត៌មាន** សូមទាក់ទងមក ៖ កញ្ញា អ័លហ្គា ណាកាចូ តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩២៨ ៩៣៤៨ / អ៊ីម៉េល onakajo@ohchr.org ឬ សរសេរទៅកាន់ srcambodia@ohchr.org*

សំរាប់**ការសាកសួរព័ត៌មាន**ពាក់ព័ន្ធនឹងអ្នកជំនាញការឯករាជ្យដទៃទៀតរបស់ អ.ស.ប ៖

សូមមេត្តាទាក់ទងមក ឈ្មោះ សាប៉ៀ ស៊ីលាយ៉ា សិទ្ធិមនុស្ស អ.ស.ប – អង្គភាពព័ត៌មាន តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩១៧ ៩៣៨៣ / អ៊ីម៉េល xcelaya@ohchr.org)

**សិទ្ធិមនុស្ស អ.ស.ប ស្វែងយល់ពីយើង តាមរយៈបណ្ដាញព័ត៌មានសង្គម ៖**

**ហ្វេសប៊ុក៖** https://www.facebook.com/unitednationshumanrights
**ទ្វីតធឺ៖** http://twitter.com/UNrightswire
**ហ្គោហ្គីល៖**Google+ gplus.to/unitednationshumanrights

**យូធូប៖** http://www.youtube.com/UNOHCHR

**បរិយាយសាច់រឿង ៖** http://storify.com/UNrightswire